ខិត្តប័ណ្ណព័ត៌មាន 1 (ខ្មែរ)

This is the Khmer factsheet.

# សេវាកម្មសុខភាព និងសុខុមាលភាពផ្លូវចិត្ត សម្រាប់មនុស្សពេញវ័យ និងមនុស្សចាស់ក្នុងមូលដ្ឋាន

រដ្ឋាភិបាលរដ្ឋវិចថូរៀ នឹងចាប់ផ្តើមបើកសេវាកម្មសុខភាព និងសុខុមាលភាពផ្លូវចិត្តសម្រាប់មនុស្សពេញវ័យ និងមនុស្សចាស់ក្នុងមូលដ្ឋាន (សេវាកម្មមូលដ្ឋាន) រហូតដល់ 60 កន្លែងពេញទូទាំងរដ្ឋវិចថូរៀ មកទល់នឹងចុងឆ្នាំ 2026។ នេះគឺជាការកែទម្រង់ដ៏សំខាន់មួយដែលបានណែនាំដោយ គណៈកម្មការស៊ើបអង្កេតសាធារណៈជាផ្លូវការ Royal Commission ក្នុងប្រព័ន្ធសុខភាពផ្លូវចិត្តរបស់រដ្ឋវិចថូរៀ (Royal Commission)។

បណ្តាញថ្មីនៃសេវាកម្មមូលដ្ឋាន នឹងក្លាយជាផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធសុខភាពផ្លូវចិត្តដែលបានកែទម្រង់របស់រដ្ឋវិចថូរៀ ដោយផ្តល់នូវវិធីងាយស្រួលក្នុងការទទួលបានការព្យាបាល និងការគាំទ្រ។ ផ្នែកផ្សេងទៀតនៃប្រព័ន្ធសុខភាពផ្លូវចិត្តក៏កំពុងពង្រីក និងផ្លាស់ប្តូរផងដែរ។ រួមគ្នា ការផ្លាស់ប្តូរទាំងនេះនឹងមានន័យថា មនុស្សដែលជួបប្រទះនឹងបញ្ហាសុខភាពផ្លូវចិត្ត ឬការទុក្ខព្រួយខាងសុខភាពផ្លូវចិត្ត អាចទទួលបានការគាំទ្រដែលពួកគេត្រូវការបានឆាប់ជាងខណៈពេលស្នាក់នៅក្នុងសហគមន៍របស់ពួកគេ ជិតក្រុមគ្រួសារ អ្នកថែទាំ និងអ្នកគាំទ្ររបស់ពួកគេ។

## តើអ្នកណាអាចប្រើប្រាស់សេវាកម្មមូលដ្ឋាន?

សេវាកម្មមូលដ្ឋាននឹងផ្តល់ការព្យាបាល ការថែទាំ និងការគាំទ្រប្រកបដោយគុណភាពខ្ពស់ ដល់ប្រជាជនដែលមានអាយុ **26 ឆ្នាំ និងលើសពីនេះ** ដែលកំពុងជួបប្រទះនឹងជំងឺផ្លូវចិត្ត ឬការទុក្ខព្រួយខាងផ្លូវចិត្ត ហើយជាអ្នកៈ

- ត្រូវការ**ការគាំទ្រច្រើន** ជាងអ្វីដែលពួកគេអាចទទួលបានពីអ្នកពិនិត្យសុខភាពទូទៅ អ្នកដោះស្រាយសុខភាពផ្លូវចិត្ត និងគ្រូពេទ្យព្យាបាលសុខភាពផ្លូវចិត្តតែឯកឯងប៉ុណ្ណោះ
- ក៏អាចមានបញ្ហាជាមួយនឹងការប្រើប្រាស់សារធាតុ ឬគ្រឿងញៀនដែរ ប៉ុន្តែ
- មិន**ត្រូវការ**ប្រភេទនៃការថែទាំប្រព័ន្ធភាពខ្ពស់ និងស្មុគស្មាញដែលផ្តល់ដោយសេវាកម្មសុខភាព និងសុខុមាលភាពផ្លូវចិត្តក្នុងតំបន់ (ដូចជាការថែទាំអ្នកជំងឺក្នុងមន្ទីរពេទ្យ)។

សម្រាប់មនុស្សដែលមានតម្រូវការខ្ពស់ ឬខុសគ្នា សេវាកម្មមូលដ្ឋាននឹងជួយក្នុងការតភ្ជាប់ពួកគេទៅកន្លែងដែលត្រឹមត្រូវ

## តើសេវាកម្មមូលដ្ឋាននឹងផ្តល់ការគាំទ្រអ្វីខ្លះ?

ស្របតាមអនុសាសន៍របស់ Royal Commission សេវាកម្មមូលដ្ឋាននឹងដាក់បញ្ចូលការពិនិត្យព្យាបាល និងសុខុមាលភាពសុខភាពផ្លូវចិត្ត ដែលនឹងផ្តល់ដោយក្រុមពហុអ្នកជំនាញសុខភាព។ សេវាកម្មនឹងរួមមានៈ

- **ការពិនិត្យ ពិភាក្សា និងការព្យាបាលសុខភាពផ្លូវចិត្ត**– ដូចជាសេវាកម្មវាយតម្លៃសុខភាពផ្លូវចិត្ត និងចិត្តសាស្ត្ររួមទាំងសម្រាប់បញ្ហាគ្រឿងស្រវឹង និងគ្រឿងញៀនដទៃទៀត
- **ការគាំទ្រសុខុមាលភាព**– ដូចជាការគាំទ្រដើម្បីជាសះស្បើយឡើងវិញ ពង្រឹងទំនាក់ទំនង បង្កើតជំនាញជីវិត ចូលរួមក្នុងសហគមន៍ និងដោះស្រាយបញ្ហានានាដូចជាជំងឺរាងកាយ ភាពគ្មានផ្ទះសម្បែង និងបញ្ហាលុយកាក់
- **ការអប់រំ ការគាំទ្រពីមិត្តភក្តិ និងការជួយខ្លួនឯង**– ឱកាសនានាដើម្បីភ្ជាប់ទំនាក់ទំនងជាមួយមនុស្សផ្សេងទៀតដែលមានមានបទពិសោធន៍ផ្ទាល់នៃជំងឺផ្លូវចិត្ត ក្រុមគ្រួសារ អ្នកថែទាំ និងអ្នកគាំទ្រដើម្បីចែករំលែកបទពិសោធន៍ និងគំនិត ហើយរៀនពីគ្នាទៅវិញទៅមក
- **ការរៀបចំផែនការ និងការសម្របសម្រួល**– ជួយក្នុងការស្វែងរក ចូលប្រើប្រាស់ និងស្ទាបស្ទង់មើលសេវាកម្មគាំទ្រសុខភាព និងសង្គមផ្សេងទៀត។

ទស្សនរបស់សេវាកម្មមូលដ្ឋានគឺ ‘តើយើងអាចជួយដោយរបៀបណា?’ សេវាកម្មមូលដ្ឋាននីមួយៗនឹងមានភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការប្លែកពិសេសរបស់សហគមន៍មូលដ្ឋាន។

## តើប្រជាជននឹងទទួលបានសេវាកម្មមូលដ្ឋានដោយរបៀបណា?

សេវាកម្មមូលដ្ឋាននឹង**មិនគិតថ្លៃ** ហើយ **ងាយស្រួលចូលប្រើប្រាស់**ដោយមិនត្រូវការការបញ្ជូន។ សេវាកម្មទាំងនេះនឹងមានម៉ោងបើកធ្វើការយូរជាង។ នឹងមានវិធីជាច្រើនដើម្បីទទួលបានការគាំទ្រ ដូចជា៖

- ទៅកន្លែង ឬ បរិដ្ឋានដែលមានសុវត្ថិភាព និងស្វាគមន៍
- មានការទៅជួបដល់ផ្ទះ ឬទីកន្លែងផ្សេងដែលមានសុវត្ថិភាព និងងាយស្រួល
- តាមទូរស័ព្ទរបស់អ្នក ឬ ការតេជាវីដេអូ។

Royal Commission បានផ្ដល់អនុសាសន៍ថា ការថែទាំត្រូវបានដឹកនាំដោយអ្នកប្រើប្រាស់ និងផ្ដោតលើមនុស្ស។ នេះមានន័យថា ប្រជាជននឹងអាចធ្វើការជាមួយសេវាកម្មមូលដ្ឋានរបស់ពួកគេ ដើម្បីរៀបចំផែនការថែទាំផ្ទាល់ខ្លួនរបស់ពួកគេ។ នៅពេលពួកគេទាក់ទងមកសេវាកម្មមូលដ្ឋានរបស់ពួកគេជាលើកដំបូង ពួកគេនឹងអាចនិយាយអំពីអ្វីដែលពួកគេត្រូវការ។ បន្ទាប់ពីនេះ បើចាំបាច់ នឹងមានការវាយតម្លៃពេញលេញលើតម្រូវការទាំងអស់របស់បុគ្គល។ ដោយផ្អែកលើផែនការថែទាំរបស់ពួកគេ ពួកគេនឹងទទួលបានការពិនិត្យព្យាបាល និងសុខុមាលភាពសុខភាពផ្លូវចិត្ត រួមទាំងការព្យាបាលលើគ្រឿងស្រវឹង និងគ្រឿងញៀន ហើយនិងការថែទាំដទៃទៀត ប្រសិនបើសមស្រប។

## តើសេវាកម្មមូលដ្ឋាននឹងដំណើរការយ៉ាងដូចម្ដេច ជាមួយផ្នែកផ្សេងទៀតនៃប្រព័ន្ធសុខភាពផ្លូវចិត្តដែលបានកែទម្រង់?

សេវាកម្មមូលដ្ឋាននឹងក្លាយជាផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធសុខភាព និងសុខុមាលភាពផ្លូវចិត្តដែលបានកែទម្រង់របស់រដ្ឋវិចថូរៀ។ ប្រព័ន្ធដែលបានកែទម្រង់មានប្រាំមួយកម្រិត (មើលរូបភាព 1)។ សេវាកម្មមូលដ្ឋានគឺជាកម្រិតទីបួន ហើយជា ‘ទ្វារខាងមុខ’ (front door) ថ្មីរបស់ប្រព័ន្ធ។ វានឹងមានភាពងាយស្រួលសម្រាប់មនុស្សក្នុងការធ្វើចលនាជុំវិញប្រព័ន្ធ និងទទួលបានការថែទាំត្រឹមត្រូវ នៅកន្លែងដែលត្រឹមត្រូវ។




*រូបភាព 1 កម្រិតនៃប្រព័ន្ធសុខភាព និងសុខុមាលភាពផ្លូវចិត្ត*

សេវាកម្មមូលដ្ឋាននឹងធ្វើការសម្ព័ន្ធភាពជាមួយអ្នកអនុវត្តទូទៅ គ្រូពេទ្យព្យាបាលសុខភាពផ្លូវចិត្ត និងអ្នកដោះស្រាយសុខភាពផ្លូវចិត្ត ហើយនិងអ្នកផ្តល់ការព្យាបាលលើគ្រឿងស្រវឹង និងគ្រឿងញៀនដទៃទៀតនៅក្នុងសហគមន៍មូលដ្ឋាន (កម្រិតទីបី)។ ឧទាហរណ៍ បុគ្គលម្នាក់អាចទទួលបានការព្យាបាលពីអ្នកអនុវត្តទូទៅរបស់ពួកគេ**និង**ការគាំទ្រសុខុមាលភាព ពីសេវាកម្មមូលដ្ឋានរបស់ពួកគេ។ ជំនួយអាចរួមមានជំនួយក្នុងការកសាងជំនាញជីវិត ឬដោះស្រាយបញ្ហាសំខាន់ដូចជាភាពគ្មានផ្ទះសម្បែង។

នៅពេលតម្រូវការរបស់បុគ្គលម្នាក់ផ្លាស់ប្តូរ ហើយពួកគេត្រូវការការព្យាបាលយ៉ាងខ្លាំងក្លាតិច ឬច្រើន ការថែទាំរបស់ពួកគេអាចត្រូវបានផ្ទេរទៅ និងមកពីសេវាកម្មក្នុងតំបន់ដោយរលូន (កម្រិតទីប្រាំ)។ ប្រជាជននឹងអាចប្រើប្រាស់សេវាកម្មក្នុងតំបន់ដោយ៖

- ការបញ្ជូនពីសេវាកម្មមូលដ្ឋានរបស់ពួកគេ
- ការបញ្ជូនពីគ្រូពេទ្យគ្រួសាររបស់ពួកគេ ឬ
- ការទៅព្យាបាលនៅមន្ទីរសង្គ្រោះបន្ទាន់។

សេវាកម្មនៅកម្រិតទីពីរ ទីបី និងទីបួន ទាំងអស់ធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធដើម្បីផ្តល់ជូនការព្យាបាល និងការថែទាំ។ ឧទាហរណ៍ សេវាកម្មមូលដ្ឋាន គ្រូពេទ្យប្រចាំគ្រួសារ អ្នកដោះស្រាយសុខភាពផ្លូវចិត្ត និងគ្រូពេទ្យព្យាបាលសុខភាពផ្លូវចិត្តធ្វើការនៅក្នុងសហគមន៍របស់ពួកគេ នឹងអាចទទួលបានដំបូន្មានពីអ្នកជំនាញពីអ្នកឯកទេសសុខភាពផ្លូវចិត្ត និងការញៀនធ្ងន់ធ្ងរ។ នេះក៏នឹងបង្កើតជំនាញ និងសមត្ថភាពរបស់សេវាកម្មមូលដ្ឋានផងដែរ។

## តើសេវាកម្មមូលដ្ឋាននឹងបើកនៅពេលណា?

មកទល់នឹងចុងឆ្នាំ 2022 សេវាកម្មមូលដ្ឋានចំនួនប្រាំមួយដំបូង នឹងបង្កើតនៅតំបន់៖

- Benalla
- Brimbank
- Frankston
- Greater Geelong
- Latrobe Valley
- Whittlesea.

មកទល់នឹងចុងឆ្នាំ 2026 យើងមានគម្រោងបង្កើតសេវាកម្មសម្រាប់ប្រជាពលរដ្ឋវិចថូរៀទាំងអស់។

## តើខ្ញុំអាចបញ្ចេញមតិអំពីសេវាកម្មមូលដ្ឋានយ៉ាងដូចម្តេច?

ផ្អែកលើរបាយការណ៍ចុងក្រោយរបស់ Royal Commission លក្ខណៈពិសេសៗជាច្រើននៃសេវាកម្មមូលដ្ឋានថ្មីត្រូវបានសម្រេចរួចរាល់ហើយ។ ទោះយ៉ាងណាក៏ដោយ នឹងមានឱកាសដើម្បីបញ្ចេញមតិអំពី៖

- អ្វីដែលអ្នកចង់បានមានបទពិសោធន៍ នៅពេលអ្នកប្រើប្រាស់សេវាកម្មមូលដ្ឋាន។
- ទម្រង់នៃគម្រូការព្យាបាល ការថែទាំ និងគាំទ្រ។

យើងនឹងប្រឹក្សាយោបល់ជាមួយអ្នកដែលមានបទពិសោធន៍ផ្ទាល់ ក្រុមគ្រួសារ អ្នកថែទាំ និងអ្នកគាំទ្រ បុគ្គលិកការងារ អ្នកផ្តល់សេវាកម្ម ស្ថាប័នកំពូល និងក្រុមតស៊ូមតិ។ នេះនឹងរួមបញ្ចូលការពិគ្រោះយោបល់ក្នុងមូលដ្ឋាន ដើម្បីស្វែងយល់ពីតម្រូវការជាក់លាក់របស់សហគមន៍នីមួយៗ។ សម្រាប់ព័ត៌មានអំពីរបៀបចូលរួម សូមចូលទៅកាន់វេទិកាEngage Victoria (ទាក់ទិនរដ្ឋវិចថូរៀ) <https://engage.vic.gov.au/ local-adult-older-adult-mental-health-wellbeing-services>

## តើគណៈកម្មការស៊ើបអង្កេតសាធារណៈជាផ្លូវការ Royal Commission ក្នុងប្រព័ន្ធសុខភាពផ្លូវចិត្តរបស់រដ្ឋវិចថូរៀ ជាអ្វី?

Royal Commission បានពិនិត្យមើលពីរបៀបបង្កើតប្រព័ន្ធសុខភាព និងសុខុមាលភាពផ្លូវចិត្ត ដែលផ្តល់នូវការព្យាបាល ការថែទាំ និងការគាំទ្រពេញលេញដល់ប្រជាពលរដ្ឋវិចថូរៀទាំងអស់។ របាយការណ៍ចុងក្រោយរបស់ The Royal Commission ត្រូវបានប្រគល់ជូននៅខែកុម្ភៈ ឆ្នាំ 2021 ហើយអាចរកបាននៅលើគេហទំព័រគណៈកម្មការស៊ើបអង្កេត

សាធារណៈជាផ្លូវការ Royal Commission ក្នុងប្រព័ន្ធសុខភាពផ្លូវចិត្តរបស់រដ្ឋវិចថូរៀ
<http://rcvmhs.archive.royalcommission.vic.gov.au/index.html>

អ្នកក៏អាចអានអំពីរបៀបដែលយើងកំពុងអនុវត្តអនុសាសន៍របស់ Royal Commission បានដែរ នៅលើ គេហទំព័រការកែទម្រង់សុខភាពផ្លូវចិត្ត Health.Vic Mental
<https://www2.health.vic.gov.au/mental-health/mental-health-reform>។

ធ្វើបច្ចុប្បន្នភាពចុងក្រោយ៖ ថ្ងៃទី 29 ខែកក្កដា ឆ្នាំ 2021

ដើម្បីទទួលបានឯកសារនេះក្នុងទម្រង់ផ្សេងទៀត សូមទូរសព្ទមកលេខ1300 650 172 ដោយប្រើសេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ 13 36 77 ប្រសិនបើតម្រូវ ឬអ៊ីម៉ែលមក ក្រុមសុខភាព និងសុខុមាលភាពផ្លូវចិត្តមនុស្សពេញវ័យ និងមនុស្សចាស់ក្នុងមូលដ្ឋាន
<localservices@health.vic.gov.au> ។

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។
© រដ្ឋវិចថូរៀ អូស្រ្តាលី ក្រសួងសុខាភិបាល ខែកក្កដា ឆ្នាំ 2021។
ISBN/ISSN 978-1-76096-487-0 (pdf/online/MS Word)
អាចរកបាននៅគេហទំព័រសេវាកម្មសុខភាព និងសុខុមាលភាពផ្លូវចិត្តសម្រាប់មនុស្សពេញវ័យ និងមនុស្សចាស់ក្នុងមូលដ្ឋាន - Engage Victoria <https://engage.vic.gov.au/local-adult-older-adult-mental-health-wellbeing-services>